# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២៩-៧-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៧១៣/៨៦៧ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **ឯម ប៊ុនសាត** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ៧៧៨២

២៩-៧-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៧១៣/៨៦៨ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយ៍ឯក **សាន ហាត់** នាយនគរបាលជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ៧៧៨៣

២៩-៧-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៧១៣/៨៦៩ ស្តីពី ការតែងតាំងឯកឧត្តម **សុខុម ទីរផល** ជាអគ្គនាយកមន្ទីរពិសោធន៍គណៈវិស្វករកម្ពុជា ៧៧៨៤

២៩-៧-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៧១៣/៨៧០ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជូនថ្នាក់ដឹកនាំក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចំនួន ០៣ រូប ពីឋានន្តរស័ក្តិវរមន្ត្រី ទៅឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ៧៧៨៥

២៩-៧-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៧១៣/៨៨១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ប្រគេនចំពោះ ព្រះពុទ្ធវង្ស **ជា សំអាង** ៧៧៨៦

២៩-៧-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៧១៣/៨៨២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ លោកជំទាវ **សម លក្ខិណា ឌុលគឿន** ៧៧៨៧

២៩-៧-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៧១៣/៨៨៣ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿង ឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ មន្ត្រីរាជការ ចំនួន ០២ រូប ៧៧៨៨

២៩-៧-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៧១៣/៨៨៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ព្រះសង្ឃ និងសប្បុរសជន ចំនួន ២៨ អង្គ/រូប ៧៧៨៩

២៩-៧-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៧១៣/៨៨៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ និងសប្បុរសជន ចំនួន ៣៩ រូប ៧៧៩០

២៩-៧-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៧១៣/៨៨៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន និងមន្ត្រីរាជការ ចំនួន ១៨ រូប ៧៧៩២

២៩-៧-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៧១៣/៨៨៧ ស្តីពី ការតែងតាំង និងតម្លើងឋានៈ ឯកឧត្តម **អ៊ុំ ម៉ារតណឹរិទ្ធ** ជាទីប្រឹក្សាអមព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ មានឋានៈស្មើ រដ្ឋលេខាធិការ ៧៧៩៣

៣១-៧-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០៧១៣/៨៨៨ ស្ដីពី ការលើកលែងទោសឱ្យទណ្ឌិតឈ្មោះ **ផេង គន្ធាម៉ូរី** ភេទស្រី អាយុ ៥៦ ឆ្នាំ ៧៧៩៤

៣១-៧-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០៧១៣/៨៨៩ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ចំពោះ ឯកឧត្ដម **ម៉ម សារិន** ៧៧៩៥

០២-៨-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៨១៣/៨៩០ ស្ដីពីការបញ្ចប់មុខតំណែង ឯកឧត្ដម **ជុំ ទឿន** ពីទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការអភិរក្សអមក្រសួងព្រះបរមរាជវាំង ៧៧៩៦

០៧-៨-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៨១៣/៨៩២ ស្ដីពី លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ៧៧៩៧

## II-រាជរដ្ឋាភិបាល

### អនុក្រឹត្យ

២៦-៦-២០១៣-អនុក្រឹត្យលេខ ៤៥៧ អនក្រ.បក ស្ដីពី ការកាត់ដីសរុបទំហំ ៦.០០២,៥ ហិកតា នៅឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង ក្នុងនោះកាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស និងកាត់ចេញពីដីសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជា កម្មសិទ្ធិជូនប្រជាពលរដ្ឋ ២.០០៥ គ្រួសារ និងរក្សាទុកមួយចំណែកជាដី សាធារណៈរបស់រដ្ឋ (ដីភ្នំ) ៧៨០៨

២៦-៦-២០១៣-អនុក្រឹត្យលេខ ៤៥៨ អនក្រ.បក ស្ដីពី ការកាត់ដីសរុបទំហំ ៦.០៤២,២៣ ហិកតា នៅស្រុកកំពង់សីលា ខេត្តព្រះសីហនុ ក្នុងនោះកាត់ចេញពី (១) ដីឧទ្យានជាតិព្រះមុនីវង្ស (២) ដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.១៧២ គ្រួសារ ៧៨១១

២៦-៦-២០១៣-អនុក្រឹត្យលេខ ៤៥៩ អនក្រ.បក ស្ដីពី ការកាត់ដីសរុបទំហំ ១.៩៣១,៦២ ហិកតា នៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ ក្នុងនោះកាត់ចេញពី (១) ដីឧទ្យានជាតិព្រះមុនីវង្ស (២) ដីគម្របព្រៃឈើឆ្នាំ ២០០២ (៣) ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អ៊ី សេង ខូអិលធីឌី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥២៩ គ្រួសារ ៧៨១៤

២៦-៦-២០១៣-អនុក្រឹត្យលេខ ៤៦០ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ២.៧៩៧,៩៤ ហិកតា នៅឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ក្នុងនោះកាត់ចេញពីដីដែនជម្រកសត្វព្រៃគូលេនព្រហ្មទេព និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លន់អេហ្គ្រីនថេតអ៊ិនវេសមេន កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន បេស្ស៊ីយ៉ាល់សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៨៥ គ្រួសារ និងរក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ៧៨១៧

២៦-៦-២០១៣-អនុក្រឹត្យលេខ ៤៦១ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ១.៩៩៧,០៣ ហិកតា នៅឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ក្នុងនោះកាត់ចេញពីដីដែនជម្រកសត្វព្រៃគូលេនព្រហ្មទេព និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លន់អេហ្គ្រីនថេតអ៊ិនវេសមេន សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៨៦ គ្រួសារ និងរក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ៧៨២០

០១-៧-២០១៣-អនុក្រឹត្យលេខ ៤៦២ អនក្រ.បក ស្តីពី ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស សានដុងសាន់សែល ស្វាយរៀង ៧៨២៣

០៨-៧-២០១៣-អនុក្រឹត្យលេខ ៤៦៣ អនក្រ.បក ស្តីពី ការបង្កើតមន្ទីរពិសោធន៍គណៈវិស្វករកម្ពុជា ៧៨២៦

១១-៧-២០១៣-អនុក្រឹត្យលេខ ៤៦៤ អនក្រ.បក ស្តីពី ការកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិ ៧៨៣១

១១-៧-២០១៣-អនុក្រឹត្យលេខ ៤៦៥ អនក្រ.បក ស្តីពី ការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់ ៧៨៣៥

០៤-៦-២០១៣ -អនុក្រឹត្យលេខ ៦៨៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៧៨៤១

០៤-៦-២០១៣ -អនុក្រឹត្យលេខ ៦៨៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៧៨៤៣

០៤-៦-២០១៣ -អនុក្រឹត្យលេខ ៦៩០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧៨៤៥

០៥-៦-២០១៣ -អនុក្រឹត្យលេខ ៦៩១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៧៨៤៦

០៥-៦-២០១៣ -អនុក្រឹត្យលេខ ៦៩២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧៨៤៧

០៥-៦-២០១៣ -អនុក្រឹត្យលេខ ៦៩៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៧៨៤៩

០៥-៦-២០១៣ -អនុក្រឹត្យលេខ ៦៩៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៧៨៥០

០៥-៦-២០១៣ -អនុក្រឹត្យលេខ ៦៩៥ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៧៨៥១

០៥-៦-២០១៣ -អនុក្រឹត្យលេខ ៦៩៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧៨៥២

០៥-៦-២០១៣ -អនុក្រឹត្យលេខ ៦៩៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៧៨៥៤

០៥-៦-២០១៣ -អនុក្រឹត្យលេខ ៦៩៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧៨៥៥

០៥-៦-២០១៣ -អនុក្រឹត្យលេខ ៦៩៩ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្ដិ នាយនគរបាលជាន់ខ្ពស់ ៧៨៥៧

០៥-៦-២០១៣ -អនុក្រឹត្យលេខ ៧០០ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្ដិ នាយនគរបាលជាន់ខ្ពស់ ៧៨៥៨

០៥-៦-២០១៣ -អនុក្រឹត្យលេខ ៧០១ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៧៨៥៩

០៥-៦-២០១៣ -អនុក្រឹត្យលេខ ៧០២ អនក្រ.តត ស្ដីពី ការតែងតាំង និងតម្លើងឋានន្តរស័ក្ដិ ជូនមន្ត្រីរាជការ ៧៨៦៦

០៥-៦-២០១៣ -អនុក្រឹត្យលេខ ៧០៣ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៧៨៦៧

០៥-៦-២០១៣ -អនុក្រឹត្យលេខ ៧០៤ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៧៨៦៩

០៥-៦-២០១៣ -អនុក្រឹត្យលេខ ៧០៥ អនក្រ.តត ស្ដីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៧៨៧១

០៦-៦-២០១៣ -អនុក្រឹត្យលេខ ៧០៦ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៧៨៧៣

០៦-៦-២០១៣ -អនុក្រឹត្យលេខ ៧០៧ អនក្រ.តត ស្ដីពី ការតែងតាំងមុខតំណែងនាយនគរបាលជាន់ខ្ពស់ ៧៨៧៤

០៦-៦-២០១៣ -អនុក្រឹត្យលេខ ៧០៨ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៧៨៧៦

០៧-៦-២០១៣ -អនុក្រឹត្យលេខ ៧០៩ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៧៨៧៧

០៧-៦-២០១៣ -អនុក្រឹត្យលេខ ៧១០ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៧៨៧៨

០៧-៦-២០១៣ -អនុក្រឹត្យលេខ ៧១១ អនក្រ.តត ស្ដីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៧៨៨០

០៧-៦-២០១៣ -អនុក្រឹត្យលេខ ៧១២ អនក្រ.តត ស្ដីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៧៨៨២

០៧-៦-២០១៣ -អនុក្រឹត្យលេខ ៧១៣ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ៧៨៨៣

០៧-៦-២០១៣ -អនុក្រឹត្យលេខ ៧១៤ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៧៨៨៤

០៧-៦-២០១៣ -អនុក្រឹត្យលេខ ៧១៥ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៧៨៨៥

០៧-៦-២០១៣ -អនុក្រឹត្យលេខ ៧១៦ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៧៨៨៦

## III. ការងារបណ្ដាក្រសួង

### ១. ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៥-៧-២០១៣ -ប្រកាសលេខ ២២០ សហវ.ប្រក ស្ដីពី ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្ដីពីការរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បងអង្គភាពថវិកា ៧៨៨៨

០៨-៨-២០១៣ -ប្រកាសលេខ ៧៣៥ សហវ.ប្រក.អពដ ស្ដីពី ការប្រមូលពន្ធប្រថាប់ត្រា ៧៨៩០

## ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល


១៥-៧-២០១៣ -ប្រកាសលេខ ៥៦៤ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្គ្រីន ឡោក បង្កើតរោងចក្រ ផលិតបេតុងលាយស្រេច ៧៨៩៦

១៥-៧-២០១៣ -ប្រកាសលេខ ៥៦៥ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ប៊ួសសាម សេនជូរី (ខេមបូឌា) បង្កើតរោងចក្រ ផលិត សម្លៀកបំពាក់ (កាត់ដេរ),ស្រោមដៃ,មួក,កន្សែង និង សម្លៀកបំពាក់ (ចាក់),ស្រោមជើង ៧៩០០

១៥-៧-២០១៣ -ប្រកាសលេខ ៥៦៦ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ៊្វូល ហ្វ័រជូន នីតធីង បង្កើតរោងចក្រ ផលិតអាវចាក់,ស្រោមជើង និងស្រោមដៃ,កន្សែង,មួក ៧៩០៤

១៥-៧-២០១៣ -ប្រកាសលេខ ៥៦៧ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជុង ហ្វៃ នីតវៀរ អេហ្វធីវ៉ាយ បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ (ចាក់) ៧៩០៨

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៣/៩៦៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **ឯម ម៉ុនសាត** អត្តលេខ ០១២០ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរល. ១៣០៧. ៩៩១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៣

លេខ: ៩៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

ស៊ុយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៣/៧៦៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ដំឡើងឋានន្តរស័ក្តិថ្នាក់**ឧត្តមសេនីយ៍ត្រី** ជូនលោកវរសេនីយ៍ឯក **សាន ចាក់ អត្តលេខ ០១៩៧៥** នាយនគរបាលជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរល. ១៣០៧. ៥៥២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៣

លេខ ៨៦៧ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៣/៥៦៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានតែងតាំងឯកឧត្តម **សុខុម ធីរផល** ជាអគ្គនាយកមន្ទីរពិសោធន៍គណៈវិស្វករកម្ពុជា ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣ខល.១៣០៧.៥៥៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៣

លេខៈ ៥៦៩ ស.ណ
**សំណៅចម្លងដែលមានតម្លៃដូចការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ ៨ ឆ្នាំ២០១៣
អគ្គលេខាធិការរង ទីស្តីការរាជរដ្ឋាភិបាល
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៣/៤៧០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១:** ដំឡើងឋានន្តរស័ក្តិជូនថ្នាក់ដឹកនាំក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចំនួន ០៣ រូប ពីឋានន្តរស័ក្តិ វរមន្ត្រី ទៅឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ៖

| ល.រ | គោត្តមនាម និង នាម | ភេទ | ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និង ថ្នាក់ | |
|---|---|---|---|---|
| | | | ចាស់ | ស្នើសុំ |
| ១ | ទេព ប៊ុន្នា | ប | វរមន្ត្រី ថ្នាក់លេខ ៧ | ឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ២ | រស់ សូរក្ខា | ស | វរមន្ត្រី ថ្នាក់លេខ ៩ | ឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៣ | ចែម សង្ការ | ប | វរមន្ត្រី ថ្នាក់លេខ ៩ | ឧត្តមមន្ត្រី ថ្នាក់លេខ ៦ |

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចនល.១៣០៧.៥៥៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៣*

លេខ: ៨១៧ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
ធ្វើនៅភ្នំពេញ ថ្ងៃទី ០១ ខែ ៨ ឆ្នាំ២០១៣
អគ្គ...ការរងទីស្ដីការរាជរដ្ឋាភិបាល
...ស័យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៣/៤៩១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ប្រគេនចំពោះ

ព្រះពុទ្ធវង្ស ជា សំអាង

ដែលមានព្រះគុណបំណាច់ដ៏ខ្ពង់ខ្ពស់ បានយកព្រះទ័យទុកដាក់ក្នុងការដឹកនាំពង្រឹងតួនាទី ដឹកនាំរបស់គណៈសង្ឃ ព្រះចៅអធិការ គណៈកម្មការវត្ត និងអាចារ្យ នៅថ្នាក់ខេត្ត ស្រុក ក្រុង ស្របតាមផ្លូវព្រះពុទ្ធសាសនា បានល្អប្រសើរ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរសេ. ១៣០៧. ៤៩៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៣*

លេខៈ ៨៧១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៣/៥៥២

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រត្ននខត្តិយា ខេមរដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

លោកជំទាវ សម លក្ខិណា ឌុលគឿន

ដែលមានគុណបំណាច់ និងស្នាដៃល្អក្នុងការបំពេញការងារជូនជាតិមាតុភូមិ និងចូលរួមចំណែក
បរិច្ចាគធនធានផ្ទាល់ខ្លួន ក្នុងការស្ថាបនាជាតិ ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ សម្រេចបានលទ្ធផលល្អប្រសើរ

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

ចនល.១៣០៧.៥៩៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៣

លេខៈ ៥៧០ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្ដីការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៣/៤៤៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការ ចំនួន ០២រូប នៃក្រសួងព័ត៌មាន ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្ម
ក្នុងការបំពេញភារកិច្ចជូនក្រសួង លើការងារគ្រប់គ្រងមន្ត្រីរាជការ តាមគោលនយោបាយ
យុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាល ទទួលបានលទ្ធផលល្អប្រសើរ

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

១- លោក គង់ សុវណ្ណ

២- លោក ហឿន សេងហាក់

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចនល. ១៣០៣៧.៤៩៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៣

លេខ: ៨៦៦ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ សីហា ឆ្នាំ២០១៣
អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៣/៥៥៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រវគ្គតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ព្រះសង្ឃ និងសប្បុរសជន ចំនួន ២៨ អង្គ/រូប មានគុណបំណាច់ និងស្នាដៃល្អ ក្នុងការចូលរួម
ជួយកសាងសមិទ្ធផលនានា លើវិស័យពុទ្ធចក្រ និងអាណាចក្រ ក្នុងខេត្តកណ្តាល កន្លងមក

នូវ

**ក-គ្រឿងឥស្សរិយយស ជាតូបការ**

| | | | | | |
|---|---|---|---|---|---|
| ១-ព្រះឃោសធម្ម | ញ៉ែម | សុគន្ធ | ២-លោក | តាន់ | សែនាយ |

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**

| | | | | | |
|---|---|---|---|---|---|
| ១-លោកជំទាវ | អៀង | ធុន្នី | ៦-លោកស្រី | រ៉េត | ផល្លីជា |
| ២-លោកជំទាវ | ខៀវ | សៅធុត្ថា | ៧-ឯកឧត្តម | នូ | សាខន |
| ៣-លោកជំទាវ | ម៉េង | សុផល | ៨-ឯកឧត្តម | សរ | មុន្នី |
| ៤-លោក | ទ៉ែត | ផល្លី | ៩-ឯកឧត្តម | ហ៊ុ | ទិរៈ |
| ៥-លោកស្រី | ឈុន | ស្រីមុំ | ១០-លោក | យី | យ៉េន |

**គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍**

| | | | | | |
|---|---|---|---|---|---|
| ១-លោកជំទាវ | សៅ | សុផានី | ៣-លោកជំទាវ | សំអឿន | ស៊ីធុត្ថា |
| ២-លោកជំទាវ | គេ | ជាលីន | | | |

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

| | | | | | |
|---|---|---|---|---|---|
| ១-លោក | ឈូ | ទិចិត្រ | ២-លោក | អ៊ុយ | សុផល |

**ង-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្ន ថ្នាក់ មហាសេនា**

| | | | | | |
|---|---|---|---|---|---|
| ១-វរសេនីយឯក | ឈឿន | សុចិត្ត | ៣-លោក | ឈឿន | ប៊ុណ្ណារ័ត្ន |
| ២-លោក | ឈឿន | ប៊ុនធន | ៤-ឧកញ៉ា | សុខ | ស្រស់ |

**ច-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**

| | | | | | |
|---|---|---|---|---|---|
| ១-ព្រះតេជគុណ | ស៊ឹម | សុខផេង | ៥-លោក | សុខ | សុវណ្ណា |
| ២-លោកស្រី | លីន | សុភារ័ត្ន | ៦-លោក | ឡាង | លន់ |
| ៣-លោក | សេង | ប៊ុនធី | ៧-លោក | ស្រេង | សុខលីម |
| ៤-លោក | មាន | ប៊ុណ្ណារិទ្ធ | | | |

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible] ១៣០៧.៥៥៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៣

លេខៈ ៨៥៥ ស.ណ
សំណៅចម្លងចេញពីច្បាប់ដើម ដើម្បីជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៣
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៣/៩៩៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការនិងសប្បុរសជន ចំនួន៣៩រូប មានស្នាដៃល្អ
ក្នុងការចូលរួមជួយកសាងនិងអភិវឌ្ឍន៍ប្រទេសជាតិ កន្លងមក

**នូវ**

**ក-គ្រឿងឥស្សរិយយសសម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្សកុសុមៈ នារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍**

១-លោក **សំ សំអាត**
២-លោក **សន កុសល**
៣-លោក **អ៊ឹក ភាលីន**
៤-វរៈសេនីយ៍ឯក **ជា ចុន្នី** អត្តលេខ០១៦៥៨៨
៥-លោក **រស់ សុខគីម**

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**

១-លោក **ម៉ុង មុន្នីចរិយា**
២-វរៈសេនីយ៍ឯក **អ៊ឹក អឿន** អត្តលេខ០១២៥

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

១-លោក **យ៉ិន សំបុន**
២-លោកស្រី **សេង ស៊ីណាត**
៣-លោក **ជា ណាឡឿន**
៤-លោកស្រី **ទួន សុភាព**
៥-លោក **គង់ ធុនខេមរិន្ទ**
៦-លោក **ស សំអឿន**
៧-លោក **សេង សុខណាក់**
៨-វរៈសេនីយ៍ទោ **ម៉ែន ចន្ថី** អត្តលេខ ០៨៣១៦
៩-លោក **ស៊ុំ មាន**
១០-លោក **ឌួង សំអាត**

**ឃ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា**

១-ឯកឧត្តម **ហេង ស៊ី**
២-លោកស្រី **នាក់ ណារិទ្ធ**
៣-វរៈនាវីទោ **គង់ សំអាត** អត្តលេខ ០២៩៣៤៣

**ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ**

១-លោក **ភង ឌីណាត**
២-លោក **ទួន ម៉ុនធុល**
៣-លោក **ហួត ចាន់ធី**
៤-លោក **ធី សារ៉ុម**

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៥-លោក ពេជ រតនា
៦-លោក ហេង ឆួច
៧-លោក ឆួន ហុង
៨-លោក ឡុង គីឡា
៩-លោក ម៉ូ ម៉ុនហាង

ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

១-លោក ហេង ហឿន
២-លោក អ៊ឹម ម៉ច
៣- លោក មុំ សំអឿន
៤-លោក ម៉ី សារឿន
៥-លោក ម៉ែន កុសល
៦-លោក សេក ជាវ៉ាឌុន្ធ
៧-លោក ឆេព ទិន
៨-លោក ឆាយ ថាន់
៩-លោក កេត គីម
១០-លោក ញ៉ែម សារឿន

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពនស. ១៣០៧. ៤៩៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៣

លេខៈ ៨៩០ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០១៣
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៣/៩៩៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន និងមន្ត្រីរាជការចំនួន ១៨ រូប ដែលបានខិតខំលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលនានាជាច្រើន និងវិស័យសង្គមកិច្ច ស្ថិតនៅក្នុងស្រុកកំចាយមារ ខេត្តព្រៃវែង

នូវ

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

លោកឧត្តមសេនីយ៍ត្រី **ស៊ិន វដ្ឋា**

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

| | |
|---|---|
| ១-ឯកឧត្តម **ដោក ណារិន** | ២-ឯកឧត្តម **ស្តើង សុខុម** |
| ៣-លោកឧត្តមសេនីយ៍ឯក **ជា សារ៉េត** | ៤-ឧកញ៉ា **ហេង ឡុង** |
| ៥-លោក **ប្រាក់ សុវណ្ណ** | ៦-លោកឧត្តមសេនីយ៍ឯក **ជឹម សារឿន** |
| ៧-លោក **ឈិល់ តារម្យ** | ៨-លោកវរសេនីយ៍ឯក **បាន ហេង** |
| ៩-លោកវរសេនីយ៍ត្រី **ខឡូ សារី** | ១០-លោកអនុសេនីយ៍ឯក **ស៊ុម រាទី** |

គ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :

| | |
|---|---|
| ១-ឯកឧត្តម **ឡាំង ប៊ុនឃន** | ២-ឯកឧត្តម **អ៊ុំ សារឿន** |
| ៣-លោក **នូ នឹម** | ៤-លោក **ម៉ាត់ សាធុជ** |

ឃ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

| | |
|---|---|
| ១-លោក **ជុំ កុសល** | ២-លោក **ឌុច គន្ធា** |
| ៣-លោកវរសេនីយ៍ទោ **ម៉ាន់ ពិសិដ្ឋ** | |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៤. ១៣០៧. ៩០០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៣

បានឃើញ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០១៣
អគ្គលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី
សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៣/៨៤៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា**
**សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ត្រាស់បង្គាប់

**តែងតាំង និងតម្លើងឋានៈ ឯកឧត្តម អ៊ុំ ម៉ារិតណូរិទ្ធ**
**ជាទីប្រឹក្សាអមព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ**
**មានឋានៈស្មើ រដ្ឋលេខាធិការ**

នរោត្តម សីហមុនី

៣៩៧.១៣០៧.៩០១

**បានប្រថាប់ព្រះរាជលញ្ឆករហើយ**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៣*

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
លេខ : ០៥៣/១៣ រ.ចច
រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៣
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឧត្តម គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៣/៨៨៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានលើកលែងទោសឱ្យទណ្ឌិតឈ្មោះ ផេង គន្ធាបូរី ភេទស្រី អាយុ ៥៦ ឆ្នាំ ដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ តាមអំណាចសាលដីកាស្ថាពរលេខ ២៥ ក្រ.II ចុះថ្ងៃទី ៣០-៤-២០១៣ របស់សាលាឧទ្ធរណ៍ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៨៨-១៣០៧-៩០២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣

លេខ ៨៦៣ ស.ណ
សំណៅដែលមានផ្ញើជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៣/៨៨៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

ឯកឧត្តម ម៉ំ បំ សារិន

ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ ដែលបានខិតខំយកអស់កម្លាំងកាយ-ចិត្ត ក្នុងការបំពេញភារកិច្ច បម្រើជាតិមាតុភូមិ កន្លងមក ទទួលបានជោគជ័យគួរអោយកោតសរសើរ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៥.១៣០៧.៩០៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣

លេខ [illegible] ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ [illegible] ខែ [illegible] ឆ្នាំ២០១៣
[illegible] រាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៣/៧៩០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ត្រាស់បង្គាប់

- បញ្ចប់មុខតំណែង ឯកឧត្តម ជុំ ទឿន ពីទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការអភិរក្ស អមក្រសួងព្រះបរមរាជវាំង ។
- ចំណុចលេខ ២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/៣១៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៩ ត្រូវទុកជានិរាករណ៍ ។
- សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

(ហត្ថលេខា)

**នរោត្តម សីហមុនី**

៣៦៦.១៣០៨.៩០៤

**បានប្រថាប់ព្រះរាជលញ្ឆករហើយ**

*ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៣*

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
លេខ [illegible] រ.ចច
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០១៣
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

(ត្រា និងហត្ថលេខា)

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៣/៧៩៦

ស្តីពី

## លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ព្រះរាជក្រឹត្យនេះមានគោលបំណងបង្កើតក្របខ័ណ្ឌដោយឡែករបស់មន្ត្រីពន្ធនាគារស្ថិតក្រោមឱវាទក្រសួងមហាផ្ទៃ ដើម្បីធានាសិទ្ធិ កាតព្វកិច្ច និងផលប្រយោជន៍ស្របច្បាប់របស់មន្ត្រីពន្ធនាគារ។

**មាត្រា ២.-**

ព្រះរាជក្រឹត្យនេះមានគោលដៅដូចតទៅ :

- កំណត់អំពីការអនុវត្តសិទ្ធិ និងភារកិច្ចរបស់មន្ត្រីពន្ធនាគារ
- កំណត់អំពីលក្ខខណ្ឌ និងលក្ខណសម្បត្តិនៃការជ្រើសរើស ការរៀបចំឋានានុក្រម ឋានន្តរសក្តិ និងមុខតំណែងរបស់មន្ត្រីពន្ធនាគារ
- កំណត់អំពីការដំឡើងថ្នាក់ ឋានន្តរសក្តិ ការដាក់ទណ្ឌកម្មខាងវិន័យ និងការចោទប្រកាន់តាមផ្លូវតុលាការដល់មន្ត្រីពន្ធនាគារ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមន្ត្រីពន្ធនាគារ ដែលកំពុងបំពេញភារកិច្ចនៅក្នុងរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ។

## ជំពូកទី២

## សិទ្ធិ កាតព្វកិច្ច និងភារកិច្ចរបស់មន្ត្រីពន្ធនាគារ

**មាត្រា ៤.-**

មន្ត្រីពន្ធនាគារត្រូវមានឧត្តមគតិស្នេហាជាតិខ្ពស់ មានភក្តីភាពចំពោះព្រះមហាក្សត្រ ហើយត្រូវគោរពវិន័យ សីលធម៌វិជ្ជាជីវៈនិងមានស្មារតីអង់អាចក្លាហាន ហ៊ានពុះពារលះបង់ ដើម្បីសម្រេចភារកិច្ចនៅគ្រប់កាលៈទេសៈ។

**មាត្រា ៥.-**

មន្ត្រីពន្ធនាគារមានសិទ្ធិ សេរីភាព និងកាតព្វកិច្ចដូចប្រជាពលរដ្ឋដទៃទៀតដែរ។ ការប្រើសិទ្ធិនិងសេរីភាព ត្រូវស្របតាមបទប្បញ្ញត្តិក្នុងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ បទបញ្ជារបស់ក្រសួងមហាផ្ទៃ និងច្បាប់នានាជាធរមាន។

**មាត្រា ៦.-**

មន្ត្រីពន្ធនាគារមានសិទ្ធិជ្រើសរើសជំនឿសាសនាដើម្បីគោរពប្រតិបត្តិ។ មន្ត្រីពន្ធនាគារមានសិទ្ធិចូលរួមក្នុងគណបក្សនយោបាយណាមួយដែលខ្លួនពេញចិត្ត ប៉ុន្តែមិនអាចសម្តែងជាសាធារណៈក្នុងពេលបំពេញភារកិច្ចតាមតួនាទីបានឡើយ។

**មាត្រា ៧.-**

មន្ត្រីពន្ធនាគារមានសិទ្ធិប្រមូលផ្តុំគ្នាបង្កើតជាសមាគមវិជ្ជាជីវៈ ឬចូលរួមជាសមាជិកសមាគមវិជ្ជាជីវៈស្របច្បាប់ណាមួយ។

**មាត្រា ៨.-**

មន្ត្រីពន្ធនាគារមានសិទ្ធិប្រើប្រាស់អាវុធនិងឧបករណ៍បច្ចេកទេស ដើម្បីធានាសន្តិសុខ សុវត្ថិភាពក្នុងនិងក្រៅបរិវេណមណ្ឌលអប់រំកែប្រែ ឬពន្ធនាគាររាជធានី ខេត្ត តាមគោលការណ៍កំណត់ ។

**មាត្រា ៩.-**

មន្ត្រីពន្ធនាគារមានសិទ្ធិសុំច្បាប់ឈប់គ្រប់ប្រភេទតាមការកំណត់របស់រាជរដ្ឋាភិបាល។ក្នុងករណីចាំបាច់មន្ត្រីពន្ធនាគារដែលកំពុងឈប់សម្រាកអាចត្រូវកោះហៅឱ្យចូលខ្លួនមកវិញបាន។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ព្រះបរមរាជវាំង

**មាត្រា ១០ .-**

មន្ត្រីពន្ធនាគារមានសិទ្ធិសុំមើលឯកសារផ្សេងៗដែលជាសំណុំរឿងផ្ទាល់ខ្លួនពាក់ព័ន្ធនឹងការទទួលទណ្ឌកម្មខាងវិន័យ ឬត្រូវផ្លាស់ប្តូរដោយបង្ខំ។ សិទ្ធិដដែលនេះត្រូវបានអនុញ្ញាតឱ្យដល់មន្ត្រីពន្ធនាគារណាយឺតយូរមិនបានឡើងឋានន្តរសក្តិតាមវេនអតីតភាព។

ក្នុងករណីពិនិត្យឃើញឯកសារសំណុំរឿងនោះមិនប្រក្រតី ឬមិនត្រឹមត្រូវ មន្ត្រីពន្ធនាគារមាន :

- សិទ្ធិសំអាងសាក្សី
- សិទ្ធិជ្រើសរើសតំណាងការពារខ្លួន
- សិទ្ធិពន្យល់ដោះសារជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ។

**មាត្រា ១១.-**

មន្ត្រីពន្ធនាគារត្រូវមានអព្យាក្រឹតភាពក្នុងតួនាទី ឬការងាររបស់ខ្លួន។ ហាមការប្រើប្រាស់តួនាទី ឬការងារនិងការប្រើប្រាស់មធ្យោបាយ សម្ភារៈរបស់រដ្ឋ ដើម្បីបម្រើសកម្មភាពនិងផលប្រយោជន៍បុគ្គល ឬអង្គការនយោបាយណាមួយ។

**មាត្រា ១២.-**

មន្ត្រីពន្ធនាគារមានកាតព្វកិច្ចរក្សាការសម្ងាត់របស់ជាតិ និងរបស់អង្គភាព។ ការផ្តល់ព័ត៌មានលិខិតស្នាម ឬឯកសារផ្ទៃក្នុងរបស់អង្គភាពដោយគ្មានការអនុញ្ញាតត្រូវហាមឃាត់។

**មាត្រា ១៣.-**

ការផ្សព្វផ្សាយក្នុងបរិវេណអង្គភាព ទោះបីជាតាមរូបភាពណាក៏ដោយដែលនាំឱ្យខូចទឹកចិត្តឬវិន័យត្រូវហាមឃាត់។ រាល់ការបកស្រាយជាសាធារណៈ ការសរសេរ ឬការធ្វើសន្និសីទសារព័ត៌មានពាក់ព័ន្ធនឹងអង្គភាពណាមួយត្រូវមានការអនុញ្ញាតពីប្រធានអង្គភាពនោះ។

**មាត្រា ១៤.-**

មន្ត្រីពន្ធនាគារត្រូវបំពេញភារកិច្ចតាមការចាត់តាំងនៅគ្រប់កាលៈទេសៈ គ្រប់ពេលវេលានិងគ្រប់ទីកន្លែង។ ប្រសិនបើភារកិច្ចនោះជួបឧបសគ្គនិងការលំបាកដែលចាំបាច់ត្រូវការឧបត្ថម្ភ ឬជំនួយ ថ្នាក់ដែលមានសមត្ថកិច្ចត្រូវជានាផ្តល់ទៅតាមលក្ខណៈជាក់ស្តែង។ ទន្ទឹមនេះមន្ត្រីពន្ធនាគារដែលទទួលភារកិច្ចនោះក៏មានសិទ្ធិសុំជំនួយអន្តរាគមន៍ពីអង្គភាពដទៃដែលនៅជិតបំផុត។

**មាត្រា ១៥.-**

មន្ត្រីពន្ធនាគារអាចនឹងត្រូវបានផ្លាស់ប្តូរទីកន្លែង ភារកិច្ច ទៅតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ។ មន្ត្រីពន្ធនាគារមានសិទ្ធិសុំផ្លាស់ប្តូរទីកន្លែងធ្វើការទៅតាមប្តី ឬតាមប្រពន្ធបាន។

**មាត្រា ១៦.-**

មន្ត្រីពន្ធនាគារត្រូវបានហាមឃាត់ជាដាច់ខាតនូវប្រការដូចខាងក្រោម :

១- យកម៉ោងបំពេញភារកិច្ចទៅប្រកបមុខរបរផ្ទាល់ខ្លួនផ្សេងៗទៀត

២- យកឥទ្ធិពលនិងអំណាចនៅក្នុងមុខងាររបស់ខ្លួន ទៅប្រើដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬដើម្បីសំឡុតគំរាមកំហែងបំពានសិទ្ធិពលរដ្ឋ ឬជនជាប់ឃុំ

៣- ប្រកបមុខរបរណាដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់មន្ត្រីពន្ធនាគារ

៤- ចូលជាសមាជិកនៃក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ ឬដោយប្រយោល

៥- បោះពុម្ពផ្សាយ ឬធ្វើការផ្សព្វផ្សាយព័ត៌មានដែលពាក់ព័ន្ធនឹងស្ថាប័ន ដោយពុំមានការអនុញ្ញាតជាមុនពីប្រធានស្ថាប័នដែលសាមីខ្លួននៅក្រោមឱវាទ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

**មាត្រា ១៧.-**

មន្ត្រីពន្ធនាគារត្រូវទទួលខុសត្រូវក្នុងការបំពេញភារកិច្ចរបស់ខ្លួនស្របតាមច្បាប់ នីតិវិធី និងក្រមសីលធម៌របស់មន្ត្រីពន្ធនាគារដែលមានជាធរមាន។ នៅពេលបំពេញបេសកកម្មការងារមានជួបគ្រោះថ្នាក់ ឬប៉ះពាល់ខាងផ្លូវច្បាប់ដោយអចេតនា រដ្ឋត្រូវគាំពារទាំងខាងមធ្យោបាយ សម្ភារ និងផ្លូវច្បាប់។

**មាត្រា ១៨.-**

មន្ត្រីពន្ធនាគារត្រូវបានទទួលពិន្ទុជារៀងរាល់ឆ្នាំសម្រាប់ពិនិត្យការដំឡើងថ្នាក់ ឋានន្តរសក្តិ។ ប្រធានអង្គភាពជាអ្នកវាយតម្លៃដាក់ពិន្ទុ និងផ្តល់មូលវិចារណ៍។

**មាត្រា ១៩.-**

មន្ត្រី ឬអង្គភាពពន្ធនាគារណាដែលមានស្នាដៃ ត្រូវបានទទួលការលើកទឹកចិត្ត ការសរសើរនិងជូនរង្វាន់តាមការកំណត់របស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## ការជ្រើសរើសមន្ត្រី

**មាត្រា ២០.-**

ការជ្រើសរើសមន្ត្រីឱ្យចូលធ្វើការក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ត្រូវធ្វើតាមរយៈការប្រឡងប្រជែងក្នុងចំណោមសិស្ស និស្សិត ឬក្នុងចំណោមមន្ត្រីរាជការដែលមានក្របខ័ណ្ឌស្រាប់។

លក្ខណសម្បត្តិជ្រើសរើសត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ២១.-**

ការប្រឡងប្រជែងចូលឋានន្តរសក្តិវរអគ្គានុរក្សថ្នាក់លេខ៣ ត្រូវបានកំណត់ដូចខាងក្រោម :

១- បេក្ខជនជានិស្សិតទាំងពីរភេទ ត្រូវមានសញ្ញាប័ត្រយ៉ាងទាបសញ្ញាប័ត្របរិញ្ញាប័ត្រឬមានសញ្ញាប័ត្រសមមូលជាមួយនឹងសញ្ញាប័ត្របរិញ្ញាប័ត្រនិងត្រូវមានអាយុយ៉ាងច្រើន ៣០ (សាមសិប)ឆ្នាំគិតដល់ថ្ងៃប្រឡង។

២- បេក្ខជនជាមន្ត្រីរាជការស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ដែលមានឋានន្តរសក្តិចាប់ពីអគ្គានុរក្សថ្នាក់លេខ៣ឡើងទៅនិងមានអតីតភាពយ៉ាងតិច០៣(បី)ឆ្នាំ ក្នុងឋានន្តរសក្តិអគ្គានុរក្សថ្នាក់លេខ៣ ឬជាមន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារដែលមានសញ្ញាប័ត្រសមមូលជាមួយនឹងសញ្ញាប័ត្របរិញ្ញាប័ត្រ ហើយមានអតីតភាពការងារយ៉ាងតិច ០៦ (ប្រាំមួយ)ឆ្នាំ និងមានអាយុយ៉ាងច្រើនបំផុត៤០(សែសិប)ឆ្នាំ គិតដល់ថ្ងៃប្រឡង។

**មាត្រា ២២.-**

ការប្រឡងប្រជែងចូលឋានន្តរសក្តិអនុរក្សថ្នាក់លេខ៣ ត្រូវធ្វើចំពោះបេក្ខជនជាសិស្ស និស្សិតទាំងពីរភេទដែលមានសញ្ញាប័ត្រយ៉ាងទាបសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិឬមានសញ្ញាប័ត្រសមមូលជាមួយនឹងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ និងត្រូវមានអាយុយ៉ាងច្រើន ២៥(ម្ភៃប្រាំ)ឆ្នាំ គិតដល់ថ្ងៃប្រឡង។

**មាត្រា ២៣.-**

ចំនួនក្របខ័ណ្ឌមន្ត្រីពន្ធនាគារដែលធ្វើការជ្រើសរើស ត្រូវកំណត់ដោយរាជរដ្ឋាភិបាលតាមសេចក្តីស្នើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ២៤.-**

បេក្ខជនទាំងពីរភេទដែលបានប្រឡងប្រជែងជាប់ចូលក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ត្រូវបានទទួលការបណ្តុះបណ្តាលជាដំបូងដោយក្រសួងមហាផ្ទៃ។ រយៈពេលបណ្តុះបណ្តាលនេះនឹងចាត់ទុកជារយៈពេលសិក្ខាកម្មសិក្សារបស់សិស្សមន្ត្រីទាំងនោះ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

មន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីសិស្ស និស្សិតត្រូវឆ្លងកាត់កម្មសិក្សាសាកល្បងរយៈពេល១២(ដប់ពីរ)ខែ។ ប្រសិនបើបេក្ខជនជាមន្ត្រីរាជការដែលបានប្រឡងជាប់ចូលក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្នុងឋានន្តរសក្តិវរអគ្គានុរក្សថ្នាក់លេខ៣ ដូចមានចែងក្នុងមាត្រា២១ ពុំចាំបាច់ឆ្លងកាត់កម្មសិក្សាសាកល្បងឡើយ។

**មាត្រា ២៥.-**

ក្រោយពេលធ្វើកម្មសិក្សាសាកល្បងសិស្សមន្ត្រីពន្ធនាគារទាំងនោះ ត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌដូចខាងក្រោម :

- សិស្សវរអគ្គានុរក្សពន្ធនាគារត្រូវបានបញ្ចូលក្របខ័ណ្ឌ និងតែងតាំងឋានន្តរសក្តិថ្នាក់វរអគ្គានុរក្សថ្នាក់លេខ៣ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- សិស្សអគ្គានុរក្សពន្ធនាគារត្រូវបានបញ្ចូលក្របខ័ណ្ឌ និងតែងតាំងឋានន្តរសក្តិថ្នាក់អនុរក្សថ្នាក់លេខ៣ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។
- ចំពោះសិស្សអគ្គានុរក្សពន្ធនាគារដែលមានសញ្ញាប័ត្របរិញ្ញាប័ត្ររងឬមានសញ្ញាប័ត្រសមមូលជាមួយនឹងសញ្ញាប័ត្របរិញ្ញាប័ត្ររងត្រូវបានតែងតាំងឋានន្តរសក្តិថ្នាក់អនុរក្សថ្នាក់លេខ១ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ២៦.-**

ក្នុងករណីក្រសួងមហាផ្ទៃពុំមានលទ្ធភាពធ្វើការបណ្តុះបណ្តាលដំបូង ក្រសួងមហាផ្ទៃអាចចាត់បញ្ជូនសិស្ស និស្សិតដែលបានប្រឡងប្រជែងជាប់ជាស្ថាពរក្នុងក្របខ័ណ្ឌ និងឋានន្តរសក្តិនីមួយៗ ឱ្យចូលបំពេញការងារនៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្តបាន។ ក្រោយពីបំពេញការងារបានរយៈពេល១២(ដប់ពីរ)ខែ សិស្ស និស្សិតទាំងនោះត្រូវបានតាំងស៊ប់និងតែងតាំងឋានន្តរសក្តិដូចបានបណ្តុះបណ្តាលដែរ។

## ជំពូកទី៤
## លំដាប់ឋានន្តរសក្តិ និងមុខតំណែង

**មាត្រា ២៧.-**

ឋានន្តរសក្តិរបស់មន្ត្រីពន្ធនាគារមាន ៣(បី) គឺ :

១- ឋានន្តរសក្តិឧត្តមអគ្គានុរក្សពន្ធនាគារ
២- ឋានន្តរសក្តិវរអគ្គានុរក្សពន្ធនាគារ
៣- ឋានន្តរសក្តិអគ្គានុរក្សពន្ធនាគារ

**មាត្រា ២៨.-**

លំដាប់ថ្នាក់ ឋានន្តរសក្តិមន្ត្រីពន្ធនាគារ មាន :

១- ឋានន្តរសក្តិឧត្តមអគ្គានុរក្សពន្ធនាគារ មាន ៣ថ្នាក់ :
- ឧត្តមអគ្គានុរក្សថ្នាក់លេខ ១
- ឧត្តមអគ្គានុរក្សថ្នាក់លេខ ២
- ឧត្តមអគ្គានុរក្សថ្នាក់លេខ ៣

២- ឋានន្តរសក្តិវរអគ្គានុរក្សពន្ធនាគារ មាន ៣ថ្នាក់ :
- វរអគ្គានុរក្សថ្នាក់លេខ ១
- វរអគ្គានុរក្សថ្នាក់លេខ ២
- វរអគ្គានុរក្សថ្នាក់លេខ ៣

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

៣- ឋានន្តរសក្តិអគ្គានុរក្សពន្ធនាគារ មាន ៧ថ្នាក់ :
- អគ្គានុរក្សថ្នាក់លេខ ១
- អគ្គានុរក្សថ្នាក់លេខ ២
- អគ្គានុរក្សថ្នាក់លេខ ៣
- អគ្គានុរក្សថ្នាក់លេខ ៤
- អនុរក្សថ្នាក់លេខ ១
- អនុរក្សថ្នាក់លេខ ២
- អនុរក្សថ្នាក់លេខ ៣

**មាត្រា ២៩.-**

ឋានន្តរសក្តិមន្ត្រីពន្ធនាគារដូចមានចែងក្នុងមាត្រា២៨ខាងលើនេះ ត្រូវមានឋានន្តរសក្តិសមមូលជាមួយនឹងឋានន្តរសក្តិមន្ត្រីរាជការស៊ីវិល និងឋានន្តរសក្តិមន្ត្រីនគរបាលជាតិនៃក្រសួងមហាផ្ទៃ។

ការកំណត់អំពីឋានន្តរសក្តិសមមូលនេះ ត្រូវធ្វើដោយអនុក្រឹត្យ។

**មាត្រា ៣០.-**

ឯកសណ្ឋាន ស្លាកសញ្ញា និងសញ្ញាសក្តិមន្ត្រីពន្ធនាគារ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៣១.-**

ឋានន្តរសក្តិឧត្តមអគ្គានុរក្សពន្ធនាគារមានឧបនិស្ស័យកាន់មុខតំណែងដូចខាងក្រោម :
- ឧត្តមអគ្គានុរក្សថ្នាក់លេខ១ ជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ
- ឧត្តមអគ្គានុរក្សថ្នាក់លេខ២ ជាអគ្គនាយករង ឬជាប្រធាននាយកដ្ឋានចំណុះអគ្គនាយកដ្ឋានពន្ធនាគារ
- ឧត្តមអគ្គានុរក្សថ្នាក់លេខ៣ ជាអនុប្រធាននាយកដ្ឋានចំណុះអគ្គនាយកដ្ឋានពន្ធនាគារ ឬជាប្រធានមណ្ឌលអប់រំកែប្រែឬជាប្រធានពន្ធនាគាររាជធានី ខេត្ត។

**មាត្រា ៣២.-**

ឋានន្តរសក្តិវរអគ្គានុរក្សពន្ធនាគារមានឧបនិស្ស័យកាន់មុខតំណែងដូចខាងក្រោម :
- វរអគ្គានុរក្សថ្នាក់លេខ១ ជាប្រធានការិយាល័យថ្នាក់កណ្តាល ឬជាអនុប្រធានមណ្ឌលអប់រំកែប្រែ ឬជាអនុប្រធានពន្ធនាគាររាជធានី ខេត្ត
- វរអគ្គានុរក្សថ្នាក់លេខ២ ជាអនុប្រធានការិយាល័យថ្នាក់កណ្តាល ឬជាប្រធានការិយាល័យនៅមណ្ឌលអប់រំកែប្រែ ឬនៅពន្ធនាគាររាជធានី ខេត្ត
- វរអគ្គានុរក្សថ្នាក់លេខ៣ ជាប្រធានផ្នែកថ្នាក់កណ្តាល ឬជាអនុប្រធានការិយាល័យនៅមណ្ឌលអប់រំកែប្រែ ឬនៅពន្ធនាគាររាជធានី ខេត្ត។

**មាត្រា ៣៣.-**

ឋានន្តរសក្តិអគ្គានុរក្សពន្ធនាគារមានឧបនិស្ស័យកាន់មុខតំណែងដូចខាងក្រោម :
- អគ្គានុរក្សថ្នាក់លេខ១ ជាអនុប្រធានផ្នែកថ្នាក់កណ្តាល ឬជាប្រធានផ្នែកនៅមណ្ឌលអប់រំកែប្រែ ឬនៅពន្ធនាគាររាជធានី ខេត្ត
- អគ្គានុរក្សថ្នាក់លេខ២ ជានាយត្រួតថ្នាក់កណ្តាល ឬជាអនុប្រធានផ្នែកនៅមណ្ឌលអប់រំកែប្រែ ឬនៅពន្ធនាគាររាជធានី ខេត្ត
- អគ្គានុរក្សថ្នាក់លេខ៣ ជានាយត្រួតរងថ្នាក់កណ្តាល ឬជាប្រធានក្រុមនៅមណ្ឌលអប់រំកែប្រែ ឬនៅពន្ធនាគាររាជធានី ខេត្ត។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

## ជំពូកទី៥
## ការដំឡើងថ្នាក់ ឋានន្តរសក្តិ

**មាត្រា ៣៤.-**

ការដំឡើងថ្នាក់ ឋានន្តរសក្តិរបស់មន្ត្រីពន្ធនាគារត្រូវគិតអំពីលក្ខណសម្បត្តិ និងអតីតភាពការងារដែលបានបំពេញក្នុងរយៈកាលកន្លងមក។

**មាត្រា ៣៥.-**

លក្ខណសម្បត្តិសម្រាប់ពិនិត្យក្នុងការស្នើដំឡើងថ្នាក់ ឋានន្តរសក្តិត្រូវផ្អែកលើ :

១- ការគោរពវិន័យ ការចាត់តាំងនិងការអនុវត្តបទបញ្ជា និងនីតិវិធីពន្ធនាគារ

២- កិរិយាមារយាទ សីលធម៌ ស្មារតីសាមគ្គីសហប្រតិបត្តិការក្នុងការបំពេញភារកិច្ច

៣- សមត្ថភាពបំពេញការងារវិជ្ជាជីវៈ បង្កើនចំណេះដឹងទូទៅ មុខជំនាញបច្ចេកទេស ភាសាបរទេស។

**មាត្រា ៣៦.-**

ការដំឡើងថ្នាក់ ឋានន្តរសក្តិរបស់មន្ត្រីពន្ធនាគារក្នុងថ្នាក់ ឋានន្តរសក្តិនីមួយៗត្រូវអនុវត្តតាមវេនជ្រើសរើសនិងតាមរយៈពេលកំណត់ដូចមានចែងខាងក្រោម :

### ១- ឋានន្តរសក្តិឧត្តមអគ្គានុរក្សពន្ធនាគារ

| ឋានន្តរសក្តិ | រយៈពេលបម្រើការងារក្នុងឋានន្តរសក្តិ ដើម្បីអាចដំឡើងបានមួយថ្នាក់ |
|---|---|
| ឧត្តមអគ្គានុរក្សថ្នាក់លេខ១ | |
| ឧត្តមអគ្គានុរក្សថ្នាក់លេខ២ | ០៥ ឆ្នាំ |
| ឧត្តមអគ្គានុរក្សថ្នាក់លេខ៣ | ០៥ ឆ្នាំ |

### ២- ឋានន្តរសក្តិវរអគ្គានុរក្សពន្ធនាគារ

| ឋានន្តរសក្តិ | រយៈពេលបម្រើការងារក្នុងឋានន្តរសក្តិ ដើម្បីអាចដំឡើងបានមួយថ្នាក់ |
|---|---|
| វរអគ្គានុរក្សថ្នាក់លេខ១ | ០៦ ឆ្នាំ |
| វរអគ្គានុរក្សថ្នាក់លេខ២ | ០៥ ឆ្នាំ |
| វរអគ្គានុរក្សថ្នាក់លេខ៣ | ០៥ ឆ្នាំ |

- វរអគ្គានុរក្សថ្នាក់លេខ១ ដែលមានអតីតភាព០៦(ប្រាំមួយ)ឆ្នាំឡើង អាចត្រូវបានស្នើសុំតែងតាំងនិងសុំដំឡើងឋានន្តរសក្តិថ្នាក់ឧត្តមអគ្គានុរក្សថ្នាក់លេខ៣ដោយយោងទៅតាមមុខតំណែងទំនេរ ឬតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

### ៣- ឋានន្តរសក្តិអគ្គានុរក្សពន្ធនាគារ

| ឋានន្តរសក្តិ | រយៈពេលបម្រើការងារក្នុងឋានន្តរសក្តិ ដើម្បីអាចដំឡើងបានមួយថ្នាក់ |
|---|---|
| អគ្គានុរក្សថ្នាក់លេខ១ | ០៣ ឆ្នាំ |
| អគ្គានុរក្សថ្នាក់លេខ២ | ០៣ ឆ្នាំ |
| អគ្គានុរក្សថ្នាក់លេខ៣ | ០៣ ឆ្នាំ |
| អគ្គានុរក្សថ្នាក់លេខ៤ | ០៣ ឆ្នាំ |
| អនុរក្សថ្នាក់លេខ១ | ០២ ឆ្នាំ |
| អនុរក្សថ្នាក់លេខ២ | ០២ ឆ្នាំ |
| អនុរក្សថ្នាក់លេខ៣ | ០១ ឆ្នាំ |

- អគ្គានុរក្សថ្នាក់លេខ១ ដែលមានអតីតភាព ៣(បី)ឆ្នាំឡើង អាចត្រូវបានទទួលការបណ្តុះបណ្តាលបន្ថែមនិងដំឡើងឋានន្តរសក្តិវរអគ្គានុរក្សថ្នាក់លេខ៣ ដោយយោងទៅតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ។

**មាត្រា ៣៧.-**

ចំពោះមន្ត្រីពន្ធនាគារដែលបានទទួលមរណភាពត្រូវបានដំឡើងថ្នាក់ ឋានន្តរសក្តិ ជាកិច្ចបច្ឆាមរណៈ។

**មាត្រា ៣៨.-**

ការដំឡើងថ្នាក់ ឋានន្តរសក្តិត្រូវប្រព្រឹត្តទៅតាមលំដាប់ថ្នាក់មួយថ្នាក់ម្តងៗ ហើយពុំអាចមានការតែងតាំងជាឋានន្តរសក្តិកិត្តិយសឡើយ។ ក្នុងករណីមន្ត្រីពន្ធនាគារណាម្នាក់បំពេញការងារមានស្នាដៃល្អពិសេសត្រូវបានដំឡើងថ្នាក់ ឋានន្តរសក្តិមួយថ្នាក់ដោយពុំគិតពីលក្ខខណ្ឌអតីតភាពឡើយ។

**មាត្រា ៣៩.-**

ការដំឡើងថ្នាក់ ឋានន្តរសក្តិរបស់មន្ត្រីពន្ធនាគារត្រូវប្រព្រឹត្តទៅតាមលំដាប់នៃបញ្ជីអតីតភាព។ ក្នុងករណីអ្នកមានអតីតភាពគ្រប់ ហើយមិនបានជាប់ឈ្មោះក្នុងតារាងដំឡើងថ្នាក់ ឋានន្តរសក្តិប្រចាំឆ្នាំ មន្ត្រីពន្ធនាគារនោះត្រូវបានទទួលសិទ្ធិចុះឈ្មោះមុនគេតាមលេខរៀងក្នុងតារាងដំឡើងថ្នាក់ ឋានន្តរសក្តិឆ្នាំបន្ទាប់ លើកលែងតែបុគ្គលនោះបានប្រព្រឹត្តអំពើល្មើសនឹងវិន័យ នីតិវិធី លក្ខន្តិកៈ ឬច្បាប់របស់រដ្ឋ។

**មាត្រា ៤០.-**

ការតែងតាំងនិងដំឡើងថ្នាក់ ឋានន្តរសក្តិ ត្រូវសម្រេចដោយ :

- ព្រះរាជក្រឹត្យ ចំពោះមន្ត្រីពន្ធនាគារស្ថិតក្នុងឋានន្តរសក្តិឧត្តមអគ្គានុរក្សពន្ធនាគារ
- អនុក្រឹត្យ ចំពោះមន្ត្រីពន្ធនាគារស្ថិតក្នុងឋានន្តរសក្តិវរអគ្គានុរក្សថ្នាក់លេខ១
- ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំពោះមន្ត្រីពន្ធនាគារចាប់ពីឋានន្តរសក្តិវរអគ្គានុរក្សថ្នាក់លេខ២ចុះ។

## ជំពូកទី៦

## បៀវត្ស និងប្រាក់បំណាច់ផ្សេងៗ

**មាត្រា ៤១.-**

មន្ត្រីពន្ធនាគារមានសិទ្ធិទទួលបៀវត្សទៅតាមឋានន្តរសក្តិ។

មន្ត្រីពន្ធនាគារអាចទទួលប្រាក់បំណាច់ផ្សេងៗតាមប្រភេទមុខងារ ឬតំណែងដែលខ្លួនបំពេញ ប្រាក់ឧបត្ថម្ភតំបន់ ប្រាក់ឧបត្ថម្ភការងារងាយប៉ះពាល់ដល់សុខភាព ប្រាក់ភោជន៍គ្រួសារ និងប្រាក់ឧបត្ថម្ភផ្សេងទៀត។

បៀវត្ស និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីពន្ធនាគារត្រូវកំណត់ដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ។

**មាត្រា ៤២.-**

មន្ត្រីពន្ធនាគារជាស្ត្រី ត្រូវបានទទួលប្រាក់ឧបត្ថម្ភលំហែមាតុភាពតាមការកំណត់របស់រាជរដ្ឋាភិបាល។

## ជំពូកទី៧

## ការចូលនិវត្តន៍

**មាត្រា ៤៣.-**

មន្ត្រីពន្ធនាគារដែលបានបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ត្រូវបានដាក់ឱ្យចូលនិវត្តន៍ រួមមាន :

ក-នៅពេលគ្រប់អាយុ ៥៥ឆ្នាំ ចំពោះមន្ត្រីពន្ធនាគារស្ថិតក្នុងឋានន្តរសក្តិអគ្គានុរក្សពន្ធនាគារ

ខ-នៅពេលគ្រប់អាយុ ៥៨ឆ្នាំ ចំពោះមន្ត្រីពន្ធនាគារស្ថិតក្នុងឋានន្តរសក្តិវរអគ្គានុរក្សពន្ធនាគារ

គ-នៅពេលគ្រប់អាយុ ៦០ឆ្នាំ ចំពោះមន្ត្រីពន្ធនាគារ ស្ថិតក្នុងឋានន្តរសក្តិឧត្តមអគ្គានុរក្សពន្ធនាគារ។

ការដាក់ឱ្យចូលនិវត្តន៍ត្រូវសម្រេចដោយ :

- ព្រះរាជក្រឹត្យ ចំពោះមន្ត្រីពន្ធនាគារមានឋានន្តរសក្តិឧត្តមអគ្គានុរក្សពន្ធនាគារ
- អនុក្រឹត្យ ចំពោះមន្ត្រីពន្ធនាគារមានឋានន្តរសក្តិវរអគ្គានុរក្សថ្នាក់លេខ១
- ប្រកាសរបស់ក្រសួងមហាផ្ទៃ ចំពោះមន្ត្រីពន្ធនាគារចាប់ពីឋានន្តរសក្តិវរអគ្គានុរក្សថ្នាក់លេខ២ចុះ។

មន្ត្រីពន្ធនាគារជាស្ត្រី ត្រូវបានដាក់ឱ្យចូលនិវត្តន៍តាមព្រះរាជក្រឹត្យលេខ នស/រកត/០៩១២/៨៤៨ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការកែសម្រួលអាយុចូលនិវត្តន៍របស់មន្ត្រីរាជការស៊ីវិលជាស្ត្រី។

## ជំពូកទី៨

## ទណ្ឌកម្ម

**មាត្រា ៤៤.-**

មន្ត្រីពន្ធនាគារដែលមានកំហុសត្រូវទទួលទណ្ឌកម្មខាងវិន័យ ដូចខាងក្រោម ៖

១-ទណ្ឌកម្មដែលកំណត់ដោយក្រមសីលធម៌ និងបទវិន័យ ឬដោយនីតិវិធីពន្ធនាគារ

២-ទណ្ឌកម្មដែលកំណត់ដោយមាត្រា៤៦នៃព្រះរាជក្រឹត្យនេះ។

**មាត្រា ៤៥.-**

ការដាក់ទណ្ឌកម្មតាមបទវិន័យ ឬនីតិវិធី ឬលក្ខន្តិកៈដោយឡែកនេះ ត្រូវសុំយោបល់ពីក្រុមប្រឹក្សាវិន័យជាមុន។

**មាត្រា ៤៦.-**

ក្រោយទទួលបានយោបល់ពីក្រុមប្រឹក្សាវិន័យ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃសម្រេចដាក់ទណ្ឌកម្ម ឬស្នើសុំដាក់ទណ្ឌកម្មខាងវិន័យ ដែលរួមមានដូចខាងក្រោម :

ក- ស្តីបន្ទោស

ខ- ការផ្លាស់ភារកិច្ចដោយបង្ខំ

គ- ការលុបឈ្មោះចេញពីតារាងដំឡើងថ្នាក់ ឋានន្តរសក្តិ

ឃ-ការដកមុខតំណែងដោយឱ្យនៅក្នុងស្ថានភាពអសកម្ម

ង- ការដាក់ឱ្យនៅទំនេរគ្មានបៀវត្ស មិនឱ្យលើសពី០១(មួយ)ឆ្នាំ

ច- ការបន្ថយថ្នាក់ ឋានន្តរសក្តិមួយថ្នាក់ឬច្រើនថ្នាក់

ឆ- ការដាក់ឱ្យចូលនិវត្តន៍មុនកំណត់

ជ- ការលុបឈ្មោះចេញពីក្របខ័ណ្ឌមន្ត្រីពន្ធនាគារ។

**មាត្រា ៤៧.-**

ការដកមុខតំណែងដោយដាក់ក្នុងស្ថានភាពអសកម្មត្រូវអនុវត្តចំពោះតែមន្ត្រីពន្ធនាគារណាដែលមិនត្រូវចូលនិវត្តន៍ភ្លាមៗ។ ការដកមុខតំណែងមិនអាចមានរយៈពេលលើសពី២(ពីរ)ឆ្នាំ។

នៅពេលផុតកំណត់នៃរយៈពេលដែលស្ថិតនៅក្នុងស្ថានភាពអសកម្ម មន្ត្រីពន្ធនាគារនោះត្រូវដាក់ឱ្យនៅក្នុងស្ថានភាពសកម្មវិញ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

រយៈពេលអសកម្មដោយការដកមុខតំណែង មិនត្រូវយកមកគិតក្នុងរយៈពេលអតីតភាពនៃការដំឡើងថ្នាក់ ឋានន្តរសក្តិទេ។

**មាត្រា ៤៨..**

មន្ត្រីពន្ធនាគារដែលត្រូវបានបន្ថយថ្នាក់ ឋានន្តរសក្តិត្រូវបញ្ចូលទៅក្នុងតារាងដំឡើងថ្នាក់ ឋានន្តរសក្តិថ្មី ចាប់គិតពីថ្ងៃដែលមានការសម្រេចជាផ្លូវការ។

## ជំពូកទី៩
## ការចោទប្រកាន់តាមផ្លូវតុលាការ

**មាត្រា ៤៩..**

ក្នុងករណីដែលមន្ត្រីពន្ធនាគារណាម្នាក់ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយត្រូវបានអាជ្ញាធរតុលាការធ្វើការចោទប្រកាន់ត្រូវជូនដំណឹងអំពីការចោទប្រកាន់ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេល ៧២(ចិតសិបពីរ)ម៉ោង យ៉ាងយូរ។

បើមានការចាប់ខ្លួន ឬការឃាត់ខ្លួន ឬការឃុំខ្លួនបណ្តោះអាសន្នលើមន្ត្រីពន្ធនាគារណាមួយនោះ អាជ្ញាធរតុលាការត្រូវរាយការណ៍ជាបន្ទាន់ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៥០..**

មន្ត្រីពន្ធនាគារណាដែលកំពុងជាប់ការចោទប្រកាន់ពីអាជ្ញាធរតុលាការ អាចត្រូវបានផ្អាកពីមុខងារសិនក្នុងករណីចាំបាច់។

ក្នុងករណីអាជ្ញាធរតុលាការសម្រេចលើកលែងការចោទប្រកាន់ជាស្ថាពរមន្ត្រីពន្ធនាគារនោះត្រូវបានទទួលឱ្យចូលធ្វើការវិញភ្លាម ដោយគិតអតីតភាពសម្រាប់ការឡើងថ្នាក់ ឋានន្តរសក្តិ និងអតីតភាពចូលនិវត្តន៍ ព្រមទាំងទទួលបៀវត្សប្រតិសកម្មផង។

**មាត្រា ៥១..**

មន្ត្រីពន្ធនាគារណាដែលត្រូវបានផ្តន្ទាទោសដោយអាជ្ញាធរតុលាការ ត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ដោយគិតពីថ្ងៃចេញសាលក្រមស្ថាពរ។

មន្ត្រីពន្ធនាគារដែលបានតវ៉ាសុំឧទ្ធរណ៍ត្រូវដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សជាបណ្តោះអាសន្នដោយស្វ័យប្រវត្តិ។

## ជំពូកទី១០
## អន្តរប្បញ្ញត្តិ

**មាត្រា ៥២..**

ក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ត្រូវបានកសាងចេញពីសមាហរណកម្មនៃក្របខ័ណ្ឌមន្ត្រីរាជការទាំងឡាយដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែងនិងមុខងារពិតប្រាកដនៅក្នុងអគ្គនាយកដ្ឋានពន្ធនាគារ ឬក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ឬក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ចំណុះក្រសួងមហាផ្ទៃ។

ការធ្វើសមាហរណកម្មក្របខ័ណ្ឌមន្ត្រីខាងលើនេះ ទៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស។

**មាត្រា ៥៣..**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងពន្ធនាគារដែលបានអនុវត្តកន្លងមកនៅមានសុពលភាពរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមខ្លឹមសារនៃព្រះរាជក្រឹត្យនេះ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

## ជំពូកទី១១
## អវសានប្បញ្ញត្តិ

**មាត្រា ៥៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥៥.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យមានប្រសិទ្ធភាព។

**មាត្រា ៥៦.-**

ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*៣៩៧.១៣០៤.៩០៦*

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា។

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

សូមចុះហត្ថលេខា។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា**

**ស ខេង**

**លេខ:៨៨៥ស.ណ**

**សំណៅចំលងមានសេចក្តីថ្លែងជាការចែកផ្សាយ**

**រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៣**

**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៦.០០២,៥ ហិកតា នៅឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង ក្នុងនោះ កាត់ចេញពីដីដែនជម្រកសត្វព្រៃភ្នំសំកុស និងកាត់ចេញពីដីសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន តាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២.០០៥ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ (ដីភ្នំ)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៧០០ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៧៧៩ ខបប ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ៦.០០២,៥ ហិកតា ក្នុងនោះ (១) ទំហំ ២៧៧ ហិកតា កាត់ចេញពីដីដែនជម្រកសត្វព្រៃភ្នំសំកុស ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៧០០ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣ និង (២) ទំហំ ៥.៧២៥,៥ ហិកតា កាត់ចេញពីដីសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ៥.៤០៦,៥ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៥៩៦ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ (ដីភ្នំ) នៅឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង ដែលស្ថិតក្នុងភូមិដូចខាងក្រោម ៖

- កាត់ផ្ទៃដីសរុបទំហំ ១.១៣៥,៥ ហិកតា ក្នុងនោះ (១) ទំហំ ៧៩,៥ ហិកតា កាត់ចេញពីដីដែនជម្រកសត្វព្រៃភ្នំសំកុស និង (២) ទំហំ ១.០៥៦ ហិកតា កាត់ចេញពីដីសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិអូរស្ងួត
- កាត់ផ្ទៃដីទំហំ ២.៧៤៤ ហិកតា ចេញពីដីសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច ដែលទំហំ ២៣១០,៥ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៤៣៣,៥ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋនៅភូមិព្រៃរំចេក

- កាត់ផ្ទៃដីសរុបទំហំ ២.១២៣ ហិកតា ក្នុងនោះ (១) ទំហំ ១៩៧,៥ ហិកតា កាត់ចេញពីដីដែនជម្រកសត្វព្រៃភ្នំសំកុស និង (២) ទំហំ ១.៩២៥,៥ ហិកតា កាត់ចេញពីដីសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច ដែលទំហំ ១.៩៦០,៥ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ១៦២,៥ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិដូនត្រីត

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ២.០០៥ គ្រួសារ នៅឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង ស្ថិតក្នុងភូមិដូចខាងក្រោម ៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥១៨ គ្រួសារ នៅភូមិអូរស្នួត
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨៣៥ គ្រួសារ នៅភូមិព្រៃរំចេក
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦៥២ គ្រួសារ នៅភូមិដូនត្រីត ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៦.០៤២,២៣ ហិកតា នៅស្រុកកំពង់សីលា ខេត្តព្រះសីហនុ ក្នុងនោះ កាត់ចេញពី(១)ដីឧទ្យានជាតិព្រះមុនីវង្ស(២) ដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើ អនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.១៧២ គ្រួសារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៧០១ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ១៣៦ សណ/១៣ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះសីហនុ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ៦.០៤២,២៣ ហិកតា ក្នុងនោះ (១) ទំហំ ៤០០,០២ ហិកតា កាត់ចេញពីដីឧទ្យានជាតិព្រះមុនីវង្ស ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៧០១ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣ (២) ទំហំ ៥.៦៤២,២១ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅឃុំកំពង់សីលា ស្រុកកំពង់សីលា ខេត្តព្រះសីហនុ ក្នុងភូមិដូចខាងក្រោម ៖

- ដីសរុបទំហំ ១.១៩៩,៥៧ ហិកតា ក្នុងនោះ (១) ទំហំ ៣៤,០៦ ហិកតា កាត់ចេញពីដីឧទ្យានជាតិព្រះមុនីវង្ស (២) ទំហំ ១.១៦៥,៥១ ហិកតា កាត់ចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិចាំស្រី
- ដីសរុបទំហំ ១.០១១,០៤ ហិកតា ក្នុងនោះ (១) ទំហំ ៦៤,១៩ ហិកតា កាត់ចេញពីដីឧទ្យានជាតិព្រះមុនីវង្ស (២) ទំហំ ៩៤៦,៨៥ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិក្រាំងអាត់
- ដីសរុបទំហំ ២.៨០៦,៦៨ ហិកតា ក្នុងនោះ (១) ទំហំ ៣០១,៧៧ ហិកតា កាត់ចេញពីដីឧទ្យានជាតិព្រះមុនីវង្ស (២) ទំហំ ២.៥០៤,៩១ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិថ្មី
- ដីទំហំ ១.០២៤,៩៤ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិវាល

តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកា ដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១ ,២,៣,៤,៥,៦,៧,៨,៩និងឧបសម្ព័ន្ធទី១០ នៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះសីហនុធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជន ជូនប្រជាពលរដ្ឋចំនួន ១.១៧២ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែងនៅ ឃុំកំពង់សីលា ស្រុកកំពង់សីលា ខេត្តព្រះសីហនុ ក្នុងភូមិដូចខាងក្រោម ៖

-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៨៩គ្រួសារនៅភូមិចាំស្រី

-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៥៣ គ្រួសារនៅភូមិក្រាំងអាត់

-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៩៨ គ្រួសារនៅភូមិថ្មី

-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៣២ គ្រួសារនៅភូមិវាល ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត ព្រះសីហនុ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គមនៅក្នុងមូលដ្ឋាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៦ ខែ[illegible] ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៥៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ១.៥៣១,៦២ ហិកតា នៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ ក្នុងនោះ កាត់ចេញពី(១) ដីឧទ្យានជាតិព្រះមុនីវង្ស (២) ដីគម្របព្រៃឈើឆ្នាំ ២០០២(៣) ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អ៊ី សេង ខូអិលធីឌី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥២៩ គ្រួសារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៧០២ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ១៣៤ សណ/១៣ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះសីហនុ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ១.៥៣១,៦២ ហិកតា ក្នុងនោះ (១) ទំហំ ១៣៦,៤៣ ហិកតា កាត់ចេញពីដីឧទ្យានជាតិព្រះមុនីវង្ស ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៧០២ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣ (២) ទំហំ ៧៥១,៤៧ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ (៣) ទំហំ ៦៤៣,៧២ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អ៊ី សេង ខូអិលធីឌី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែងនៅឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ក្នុងភូមិដូចខាងក្រោម៖

- ដីសរុបទំហំ ៤១០,០៥ ហិកតា ក្នុងនោះ (១) ទំហំ ១៣៦,៤៣ ហិកតា កាត់ចេញពីដីឧទ្យានជាតិព្រះមុនីវង្ស (២) ទំហំ ១២៥,៦៦ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ (៣) ទំហំ ១៤៧,៩៦ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អ៊ី សេង ខូអិលធីឌី សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិព្រែកប្រស់
- ដីសរុបទំហំ ៣៣៤,៦៩ ហិកតា ក្នុងនោះ (១) ទំហំ ១៤៥,៤៧ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ (២) ទំហំ ១៨៩,២២ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អ៊ី សេង ខូអិលធីឌី សម្រាប់ធ្វើប្រទានកម្ម ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅភូមិព្រែកទាល់
- ដីសរុបទំហំ ២០៩,៣៦ ហិកតា ក្នុងនោះ (១) ទំហំ ៦៣,៣៥ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ (២) ទំហំ ១៤៦,០១ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អ៊ី សេង ខូអិលធីឌី សម្រាប់ធ្វើប្រទានកម្ម ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅភូមិព្រែកសង្កែ
- ដីសរុបទំហំ ៥៧៧,៥២ ហិកតា ក្នុងនោះ (១) ទំហំ ៤១៦,៩៩ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ (២) ទំហំ ១៦០,៥៣ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ច

របស់ក្រុមហ៊ុន អ៊ី សេង ខូអិលធីឌី សម្រាប់ធ្វើប្រទានកម្ម ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅភូមិកំពង់ចិន

តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១ ,២,៣,៤,៥,៦,៧,៨និងឧបសម្ព័ន្ធទី៩ នៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះសីហនុ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៥២៩ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែងនៅឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ក្នុងភូមិដូចខាងក្រោម៖

-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២០៧ គ្រួសារនៅភូមិព្រែកប្រស់

-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១០៩ គ្រួសារនៅភូមិព្រែកទាល់

-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១០៩ គ្រួសារនៅភូមិព្រែកសង្កែ

-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១០៤ គ្រួសារនៅភូមិកំពង់ចិន ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះសីហនុ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គមនៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៤៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ២.៧៥៧,៩៤ហិកតា នៅឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ក្នុងនោះកាត់ចេញពីដីដែនជម្រកសត្វព្រៃគូលេនព្រហ្មទេព និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ កាត់ចេញពីដី សម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លន់អេហ្គ្រីនថេតអ៊ិនវេសមេន កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនបេសរ៉ូយ៉ាល់ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៤៥គ្រួសារ និងរក្សាទុក មួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៧០៣ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១០៤៥ ឧ.ជ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រង ដីរដ្ឋខេត្តឧត្តរមានជ័យ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ២.៧៥៧,៩៤ ហិកតា ក្នុងនោះ (១) ទំហំ ១៥៨,១៥ ហិកតា កាត់ចេញពីដីដែនជម្រកសត្វព្រៃគូលេនព្រហ្មទេព ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៧០៣ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣ (២) ទំហំ ១.៨០៨,៩១ ហិកតា និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លន់អេហ្គ្រីនថេត អ៊ិនវេសមេន និង (៣) ទំហំ ៧៩០,៨៨ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន បេស រ៉ូយ៉ាល់ ដែលទំហំ ១.៥៩០,០៥ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៤៥ គ្រួសារ និងទំហំ ១.១៦៧,៨៩ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិអូរក្រូច ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ចំនួន ៣៤៥ គ្រួសារ នៅនៅភូមិអូរក្រូច ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

**មាត្រា ៣..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧១.....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ១.៩៩៧,០៣ ហិកតា នៅឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ក្នុងនោះ កាត់ចេញពីដីដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនលន់អៀហ្គ្រីនថេតអ៊ិនវេសមេន សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៤៦ គ្រួសារ និងរក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៧០៤ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១០៤៦ ឧ.ជ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រង ដីរដ្ឋខេត្តឧត្តរមានជ័យ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ១.៩៩៧,០៣ ហិកតា ក្នុងនោះ (១) ទំហំ ១.៤៤៨,៦៧ ហិកតា កាត់ចេញពីដីដែនជម្រកសត្វព្រៃគូលេនព្រហ្មទេព ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៧០៤ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និង (២) ទំហំ ៥៤៨,៣៦ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លន់អេហ្គ្រីនថេត អ៊ិនវេសមេន ដែលទំហំ ១.៤៤៤,៨៨ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៥៥២,១៥ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិអូរក្រោច ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ចំនួន ៣៤៦ គ្រួសារ នៅភូមិអូរក្រោច ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៤៦៧.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស សានដុង សាន់សែល ស្វាយរៀង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១

នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**មាត្រា១.-**

បង្កើត **តំបន់សេដ្ឋកិច្ចពិសេស សានដុង សាន់សែល ស្វាយរៀង** ( **SHANDONG SUNSHELL SVAY RIENG SEZ**) ដែលមានទីតាំងស្ថិតនៅភូមិជ្រៃធំ ឃុំព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង ។

**មាត្រា២.-**

**តំបន់សេដ្ឋកិច្ចពិសេស សានដុង សាន់សែល ស្វាយរៀង** មានទំហំ ៩៦,១៤ ហិកតា (កៅសិបប្រាំមួយហិកតា និងដប់បួនអា) ដូចមានប្លង់ទីតាំងព្រំប្រទល់ភូមិសាស្ត្រក្នុងឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ ។

**មាត្រា៣.-**

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេស សានដុង សាន់សែល ស្វាយរៀង** ដូចមានកំណត់ក្នុងមាត្រា ២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន ។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃ **តំបន់សេដ្ឋកិច្ចពិសេស សានដុង សាន់សែល ស្វាយរៀង** នេះ នឹងស្ថិតក្រោមវិសាលភាព នៃច្បាប់ និងបទប្បញ្ញត្តិនានា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង និងក្រុមហ៊ុន សានដុង សាន់សែល អ៊ិនធើណេសិនណល (ខេមបូឌា) ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

ដើម្បីសុំចុះហត្ថលេខា

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

**សុខ ចិន្តា សោភា**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៦៣ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការបង្កើតមន្ទីរពិសោធន៍គណៈវិស្វករកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៨/៣៤៦ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៨ ស្ដីពីគោលការណ៍រួមនៃការបង្កើតនិងការដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩ ស្ដីពីការបង្កើតគណៈវិស្វករកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈវិស្វករកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតនិងដាក់ឲ្យដំណើរការមន្ទីរពិសោធន៍គណៈវិស្វករកម្ពុជា ដែលសរសេរជាអក្សរកាត់ថា **ម.ត.វិ.ក.** ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈវិស្វករកម្ពុជា ដោយមានអគ្គលេខាធិការដ្ឋានគណៈវិស្វករកម្ពុជាជាសេនាធិការសម្របសម្រួលក្នុងដំណើរប្រព្រឹត្តទៅរបស់ **ម.ត.វិ.ក.** នេះ។

**មាត្រា២ .-**

**ម.គ.វិ.ក.** ត្រូវបានបង្កើតឡើងក្នុងគោលបំណងសំខាន់ៗដូចខាងក្រោម៖

- ផ្តល់ឲ្យគណៈវិស្វករកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រង ត្រួតពិនិត្យ វិភាគ តាមដាន និងធ្វើកោសលវិច័យ លើការប្រកបវិជ្ជាជីវៈវិស្វកម្មនៅព្រះរាជាណាចក្រកម្ពុជា
- សហការបណ្តុះបណ្តាលបំប៉នវិជ្ជាជីវៈវិស្វកម្មជាក់ស្តែងដល់វិស្វករចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីអភិវឌ្ឍសមត្ថភាពក្នុងការប្រតិបត្តិវិជ្ជាជីវៈវិស្វកម្មគ្រប់មុខជំនាញទាំងទ្រឹស្តីទាំងបទពិសោធ ឲ្យមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមស្តង់ដាកំណត់ ឆ្លើយតបបានទៅនឹងតម្រូវការទីផ្សារពលកម្មក្នុងស្រុក តំបន់ និងអន្តរជាតិ
- បង្កលក្ខណៈងាយស្រួលដល់គណៈវិស្វករកម្ពុជា ដើម្បីធ្វើការសិក្សា វិភាគ វាយតម្លៃគុណភាពសម្ភារៈបរិក្ខារសម្រាប់ប្រើប្រាស់ក្នុងវិស័យវិស្វកម្ម
- តាមដានការងារអនុវត្តរបស់វិស្វករអាជីពដើម្បីធ្វើការណែនាំផ្នែកបច្ចេកទេសក្នុងការងារវិស្វកម្ម ដើម្បីធានានូវក្រមសីលធម៌វិជ្ជាជីវៈ គុណភាព សោភណភាព និងការសន្សំសំចៃ
- សហការជាមួយដៃគូអភិវឌ្ឍឬក្រុមហ៊ុនឯកជននានា ដើម្បីឲ្យ **ម.គ.វិ.ក.** មានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវានិងអភិវឌ្ឍខ្លួន។

## ជំពូកទី២
## តួនាទីនិងភារកិច្ច

**មាត្រា៣ .-**

**ម.គ.វិ.ក.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ធ្វើការសិក្សាស្រាវជ្រាវបច្ចេកទេសថ្មីៗតាមសម័យនិយម លើមុខជំនាញវិស្វកម្ម ព្រមទាំងចូលរួមសហការកសាងបទដ្ឋានបច្ចេកទេសនានាពាក់ព័ន្ធវិជ្ជាជីវៈវិស្វកម្ម ដើម្បីធ្វើការផ្សព្វផ្សាយដល់វិស្វករសម្រាប់អនុវត្តទូទាំងប្រទេស
- កំណត់ពីស្តង់ដានៃគុណភាពប្រភេទសម្ភារៈបរិក្ខារសម្រាប់ប្រើប្រាស់ក្នុងវិស័យវិស្វកម្ម
- សហការជាមួយមន្ទីរពិសោធន៍ដែលមានស្រាប់ នៅតាមក្រសួង មន្ទីរ សហគ្រាស គ្រឹះស្ថានឧត្តមសិក្សានានា ដើម្បីទទួលបាននូវស្តង់ដាបទដ្ឋានបច្ចេកទេសជាតិមួយសម្រាប់ផ្សព្វផ្សាយនិងអនុវត្ត
- ធ្វើការណែនាំ ផ្តល់យោបល់ និងផ្តល់ជំនួយបច្ចេកទេស កោសលវិច័យ ពិនិត្យកំហុសឆ្គងក្នុងវិស័យវិស្វកម្មដល់វិស្វករចុះបញ្ជី
- សហការជាមួយដៃគូអភិវឌ្ឍនិងក្រុមហ៊ុនឯកជនដើម្បីឲ្យ **ម.គ.វិ.ក.** មានសមត្ថភាពពេញលក្ខណសម្បត្តិក្នុងការផ្តល់សេវា និងបណ្តុះបណ្តាល បង្កើនសមត្ថភាពជំនាញវិជ្ជាជីវៈវិស្វកម្មដល់វិស្វករចុះបញ្ជី
- ទទួលកម្មសិក្សាការីអ្នកបច្ចេកទេស សម្រាប់បណ្តុះបណ្តាលឲ្យមានវិជ្ជាជីវៈជំនាញពិតប្រាកដ
- រៀបចំសារណាបច្ចេកទេស ដោយប្រមូលព័ត៌មានទិន្នន័យដែលទទួលបាន ក្នុងពេលបំពេញបេសកកម្ម និងតួនាទីភារកិច្ចរបស់ខ្លួន។

**មាត្រា៤ ._**

សិទ្ធិនិងការទទួលខុសត្រូវរបស់ប្រធាន **ម.គ.ទិ.ភ.** ត្រូវកំណត់ឱ្យបានច្បាស់លាស់នៅក្នុងលក្ខខណ្ឌ តួនាទីភារកិច្ច និងកិច្ចសន្យាគ្រប់គ្រងការផ្តល់សេវា។

លក្ខខណ្ឌតួនាទីភារកិច្ច និងកិច្ចសន្យាគ្រប់គ្រងការផ្តល់សេវាគំរូជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## ការគ្រប់គ្រងបុគ្គលិក

**មាត្រា៥ ._**

**ម.គ.ទិ.ភ.** ត្រូវបានដឹកនាំនិងគ្រប់គ្រងដោយប្រធានមួយរូបដែលមានឋានៈស្មើអគ្គនាយក និងអមដោយអនុប្រធានមួយចំនួនតាមការចាំបាច់ ដែលមានឋានៈស្មើអគ្គនាយករង។

ប្រធាន **ម.គ.ទិ.ភ.** ត្រូវទទួលខុសត្រូវក្នុងការរៀបចំដំណើរការ និងការគ្រប់គ្រងទីភ្នាក់ងារប្រតិបត្តិការពិសេសរបស់ខ្លួន ចំពោះប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា។

ប្រធាន **ម.គ.ទិ.ភ.** ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនិងដំណើរការការងារជូនប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា។

បុគ្គលិកបម្រើការងារនៅ **ម.គ.ទិ.ភ.** ជាមន្ត្រីមុខងារសាធារណៈឬមន្ត្រីជាប់កិច្ចសន្យារបស់គណៈវិស្វករកម្ពុជា។

**មាត្រា៦ ._**

**ម.គ.ទិ.ភ.** ត្រូវបានអនុញ្ញាតឱ្យប្រើត្រាដោយឡែក។

## ជំពូកទី៤
## រចនាសម្ព័ន្ធ

**មាត្រា៧ ._**

**ម.គ.ទិ.ភ.** មានបីផ្នែក តាមរចនាសម្ព័ន្ធដូចខាងក្រោម៖

- ផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- ផ្នែកបច្ចេកទេស
- ផ្នែកសហប្រតិបត្តិការនិងផ្តល់សេវា។

ផ្នែកនីមួយៗត្រូវដឹកនាំនិងគ្រប់គ្រងដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនតាមការចាំបាច់។ ការកំណត់តួនាទីភារកិច្ចនិងការងារទទួលខុសត្រូវរបស់ប្រធានផ្នែកនីមួយៗ ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ប្រធាន **ម.គ.ទិ.ភ.**។

**មាត្រា៨ ._**

ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុមានតួនាទីនិងភារកិច្ចដូចតទៅ៖

- ចាត់ចែង ចរាចរណ៍និងគ្រប់គ្រងឯកសាររដ្ឋបាល
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារ

- គ្រប់គ្រងបុគ្គលិក រៀបចំការងារបៀវត្សរ៍ពលកម្ម ប្រាក់កម្រៃ របបឧបត្ថម្ភ ឬប្រាក់លើកទឹកចិត្ត ដល់បុគ្គលិកក្របខ័ណ្ឌមុខងារសាធារណៈនិងបុគ្គលិកជាប់កិច្ចសន្យា
- រៀបចំ តាក់តែងលិខិតបទដ្ឋានគតិយុត្ត លិខិតរដ្ឋបាលនានា និងធ្វើកំណត់ហេតុប្រជុំ
- ធ្វើរបាយការណ៍ការងារនិងកំណត់ហេតុផ្សេងៗរបស់ថ្នាក់ដឹកនាំ
- ធ្វើរបាយការណ៍សរុបលទ្ធផលនិងសកម្មភាពការងាររបស់ **ម.គ.វិ.ក.** ជាប្រចាំ និងធ្វើរបាយការណ៍បូកសរុបការងារប្រចាំខែ ឆមាស និងប្រចាំឆ្នាំ
- ប្រមូលទិន្នន័យស្តីពីសកម្មភាពការងារ និងលើកគម្រោងថវិកាសម្រាប់ដំណើរការ **ម.គ.វិ.ក.**
- ផ្គត់ផ្គង់និងគ្រប់គ្រងមូលដ្ឋានសម្ភារៈបរិក្ខារ **ម.គ.វិ.ក.**
- គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ សន្និធិ សម្ភារៈ និងបញ្ជីសារពើភណ្ឌ។

**មាត្រា៩ .-**

ផ្នែកបច្ចេកទេស មានតួនាទីនិងភារកិច្ចដូចតទៅៈ

- ប្រមូល ពិនិត្យ វិភាគ និងចងក្រងទិន្នន័យលទ្ធផលការងាររបស់ **ម.គ.វិ.ក.** កំណត់ស្តង់ដាបទដ្ឋានបច្ចេកទេសមួយ ដើម្បីធ្វើការផ្សព្វផ្សាយនិងអនុវត្តទូទាំងប្រទេស
- វិភាគនិងកំណត់ស្តង់ដាគុណភាពនៃប្រភេទ សម្ភារៈបរិក្ខារ សម្រាប់ប្រើប្រាស់ក្នុងវិស័យវិស្វកម្ម
- ផ្តល់យោបល់បច្ចេកទេសលើការអនុវត្តគម្រោងវិស្វកម្មក្នុងករណីមានភាពមិនប្រក្រតី
- ធ្វើការណែនាំ ផ្តល់យោបល់ និងផ្តល់ជំនួយបច្ចេកទេសដល់វិស្វករអាជីព ជៀសវាងនូវកំហុសឆ្គងក្នុងការអនុវត្តការងារវិស្វកម្ម
- ប្រមូលផ្តុំនិងចងក្រងនូវទិន្នន័យដែលទទួលបាន ក្នុងពេលបំពេញតួនាទីភារកិច្ចរបស់ខ្លួន
- លើកគម្រោងនៃតម្រូវការនិងការថែទាំសម្ភារៈបរិក្ខារបច្ចេកទេសរបស់ **ម.គ.វិ.ក.**។

**មាត្រា១០ .-**

ផ្នែកសហប្រតិបត្តិការនិងផ្តល់សេវាមានតួនាទីនិងភារកិច្ចដូចតទៅៈ

- សហការជាមួយដៃគូអភិវឌ្ឍនិងក្រុមហ៊ុនឯកជននានាក្នុងការអភិវឌ្ឍ និងផ្តល់សេវារបស់ **ម.គ.វិ.ក.**
- សហការជាមួយផ្នែកអប់រំនិងបណ្តុះបណ្តាលនៃអគ្គលេខាធិការដ្ឋានគណៈវិស្វករកម្ពុជា និងដៃគូអភិវឌ្ឍ រៀបចំផែនការសម្រាប់បណ្តុះបណ្តាល បង្ហាត់បង្រៀនបច្ចេកទេស បង្កើនសមត្ថភាពជំនាញវិជ្ជាជីវៈវិស្វកម្មដល់វិស្វករចុះបញ្ជី។

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា១១ .-**

ប្រភពធនធានថវិការបស់ **ម.គ.វិ.ក.**ៈ

- ថវិកាជាតិដែលជាឧបសម្ព័ន្ធនៃថវិការបស់គណៈវិស្វករកម្ពុជា
- ថវិកាដែលបានមកពីការបែងចែកកម្រៃសេវា
- ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍនិងពីប្រភពផ្សេងៗទៀត។

**មាត្រា១២ ._**

ការកំណត់ថ្លៃសេវានិងការបែងចែកកម្រៃសេវាជាមួយដៃគូអភិវឌ្ឍឬក្រុមហ៊ុនឯកជននានា ត្រូវធ្វើឡើងដោយប្រកាសរួមរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៣ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា អគ្គលេខាធិការដ្ឋានគណៈវិស្វករកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និងជាប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៦៤ អនក្រ.បក

## អនុក្រឹត្យ
ស្តីពី
**ការកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែ**
**ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិ**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិ ។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ជាថ្មីនូវកម្រិតនៃប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិ។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់លើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិទាំងអស់នៅទូទាំងប្រទេស។

## ជំពូកទី២

## ការកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែ

**មាត្រា ៤.-**

ត្រូវបានកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិដូចខាងក្រោម៖

១- ប្រធានក្រុមប្រឹក្សា និងជាមេឃុំ ចៅសង្កាត់ក្នុងមួយនាក់ ៣០០.០០០រៀល (បីរយពាន់រៀល) ក្នុងមួយខែ

២- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាជំទប់ទី១ និងជំទប់ទី២ ចៅសង្កាត់រងទី១ និងចៅសង្កាត់រងទី២ ក្នុងមួយនាក់ ២៤០.០០០រៀល (ពីររយសែសិបពាន់រៀល) ក្នុងមួយខែ

៣- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមិនស្ថិតក្នុងមុខតំណែងខាងលើ ក្នុងមួយនាក់ ២០០.០០០រៀល (ពីររយពាន់រៀល) ក្នុងមួយខែ

៤- មេភូមិក្នុងមួយនាក់ ១២០.០០០រៀល (មួយរយម្ភៃពាន់រៀល) ក្នុងមួយខែ

៥- អនុប្រធានភូមិក្នុងមួយនាក់ ១០០.០០០រៀល (មួយរយពាន់រៀល) ក្នុងមួយខែ

៦- សមាជិកភូមិក្នុងមួយនាក់ ៨០.០០០រៀល (ប៉ែតសិបពាន់រៀល) ក្នុងមួយខែ។

**មាត្រា ៥.-**

ការផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិ ដូចបានកំណត់ក្នុងមាត្រា៤ខាងលើ ត្រូវអនុវត្តចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិដែលស្ថិតក្នុងមុខតំណែងតែប៉ុណ្ណោះ។

ការផ្តល់ប្រាក់ឧបត្ថម្ភនេះ ត្រូវគ្រោងនិងបើកផ្តល់នៅក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ដោយគិតពីខែមករា ឆ្នាំ២០១៤ តទៅ។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**មាត្រា ៦.-**

អនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ស្តីពីការកំណត់ប្រាក់បំណាច់ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រាក់ឧបត្ថម្ភចំពោះមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវទុកជានិរាករណ៍។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អភិបាលនៃគណៈអភិបាលក្រុង ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងមេឃុំ ចៅសង្កាត់ទាំងអស់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>កន្លែងទទួល:</u>**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
